# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

លេខ:.....៥៤១.....សហវ/អគហ....

## សេចក្តីជូនដំណឹង

### ស្តីពី អាហារូបករណ៍កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៤
### ក្រោមជំនួយឧបត្ថម្ភពីអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងសាលាលីក្វាន់យូនៃប្រទេសសិង្ហបុរី

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជម្រាបជូនដំណឹងដល់គ្រប់ក្រសួង-ស្ថាប័ន នៃរាជរដ្ឋាភិបាលកម្ពុជា មេត្តាជ្រាបថា÷ ស្របតាមស្មារតីនៃអនុស្សរណៈយោគយល់គ្នា, **អ.គ.ហ.** បានសហការជាមួយសាលាគោលនយោបាយសាធារណៈលីក្វាន់យូនៃប្រទេសសិង្ហបុរី ក្នុងក្របខណ្ឌភាពជាដៃគូដើម្បីផ្តល់អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ សិក្សានៅសាលាលីក្វាន់យូ ជូនមន្ត្រីរាជការគ្រប់រូបដែលបម្រើការងារនៅតាមក្រសួង-ស្ថាប័ន និងក្នុងក្របខណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងគោលបំណងពង្រឹងការកសាងសមត្ថភាពរបស់មន្ត្រីរាជការ។ ក្នុងន័យនេះ **អ.គ.ហ.** សូមជូនដំណឹងជាសាធារណៈស្តីពីការជ្រើសរើសបេក្ខជនអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ ឆ្នាំសិក្សា ២០២៤-២០២៥ លើមុខជំនាញដូចខាងក្រោម÷

១. ជំនាញរដ្ឋបាលសាធារណៈ (Master in Public Administration-MPA) រយៈពេលសិក្សា ០១ ឆ្នាំ

២. ជំនាញគោលនយោបាយសាធារណៈ (Master in Public Policy-MPP) រយៈពេលសិក្សា ០២ ឆ្នាំ

### ក. អត្ថប្រយោជន៍អាហារូបករណ៍

បេក្ខជនដែលជាប់អាហារូបករណ៍កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងទទួលបានអត្ថប្រយោជន៍ រួមមាន ថ្លៃសិក្សា ប្រាក់អាហារូបករណ៍ ថ្លៃសំបុត្រយន្តហោះកម្ពុជា-សិង្ហបុរី (ពេលចេញដំណើរ និងពេលបញ្ចប់ការសិក្សា)។

### ខ. លក្ខខណ្ឌជ្រើសរើសបេក្ខនាព

១. មានសញ្ជាតិខ្មែរ

២. ជាមន្ត្រីរាជការក្របខណ្ឌមុខងារសាធារណៈ (មន្ត្រីរាជការដែលបម្រើការងារនៅក្នុងក្របខណ្ឌនៃក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួង-ស្ថាប័នត្រូវបានផ្តល់អាទិភាពខ្ពស់)

៣. យ៉ាងហោចណាស់មានសញ្ញាបត្របរិញ្ញាបត្រ និងមានពិន្ទុនៃការសិក្សាល្អ

៤. បទពិសោធន៍ការងារ ÷

- សម្រាប់ជំនាញ MPA ÷ យ៉ាងហោចណាស់ ៥ឆ្នាំ លើការងារពាក់ព័ន្ធ
- សម្រាប់ជំនាញ MPP ÷ យ៉ាងហោចណាស់ ៣ឆ្នាំ លើការងារពាក់ព័ន្ធ

៥. ពិន្ទុ IELTS ៧.០ ឬ TOEFL ibt ១០០ ឬ លិខិតបញ្ជាក់ពីសាកលវិទ្យាល័យអំពីកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្ររបស់បេក្ខជនជាភាសាអង់គ្លេស



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ: (+៨៥៥) ២៣ ៨៩០ ៦៦៦
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA Phone: (+855) 23 890 666

## គ. ឯកសារដែលបេក្ខជនត្រូវភ្ជាប់មកជាមួយ

- ប័ណ្ណសំគាល់មន្ត្រីរាជការ ឬវិញ្ញាបនបត្ររដ្ឋបាលចេញដោយក្រសួង-ស្ថាប័ន (ច្បាប់ចម្លង ១ ច្បាប់)
- សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ភ្ជាប់ជាមួយនឹងព្រឹត្តិបត្រពិន្ទុ (ច្បាប់ចម្លង ១ ច្បាប់)
- លិខិតបញ្ជាក់ពិន្ទុ IELTS ៧.០ ឬ TOEFL ibt ១០០ ឬលិខិតបញ្ជាក់ពីសាកលវិទ្យាល័យអំពីកម្មវិធីសិក្សាជាភាសាអង់គ្លេស (ច្បាប់ចម្លង ១ ច្បាប់)
- ប្រវត្តិរូបសង្ខេប ភ្ជាប់ជាមួយ Motivation Letter ជាភាសាអង់គ្លេស

****សំគាល់÷**

បេក្ខភាពដែលជាប់ក្នុងបញ្ជីជ្រើសរើសដំបូង (shortlist) នឹងត្រូវបានទាក់ទងដោយផ្ទាល់ពីសាលាលីក្វាន់យូ ដើម្បីណែនាំនីតិវិធីរៀបចំសំណុំឯកសារស្នើសុំអាហារូបករណ៍ទៅតាមលក្ខខណ្ឌចាំបាច់ដែលកំណត់ដោយសាលា និងវាយតម្លៃជ្រើសរើសចុងក្រោយ។ បេក្ខជនដែលជាប់ជាស្ថាពរ នឹងត្រូវគោរពតាមគោលការណ៍របស់ **អ.គ.ហ.** និងសាលាលីក្វាន់យូ។

## ឃ. កាលបរិច្ឆេទ និងកន្លែងទទួលពាក្យ

បេក្ខជន/បេក្ខនារីដែលមានបំណងចូលរួមក្នុងកម្មវិធីអាហារូបករណ៍នេះ សូមផ្ញើឯកសារភ្ជាប់ឱ្យបានត្រឹមត្រូវដូចរៀបរាប់ខាងលើ មកអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានអាសយដ្ឋាន÷ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគារ "ក" ជាន់ទី៣ ឬផ្ញើទៅអ៊ីម៉ែល scholarship@pfm.gov.kh ចាប់ពីថ្ងៃផ្សាយដំណឹងនេះរហូតដល់ថ្ងៃទី២៣ ខែ.តុលា. ឆ្នាំ២០២៣ (ត្រឹមម៉ោង៥ល្ងាច)។ សម្រាប់ព័ត៌មានបន្ថែម បេក្ខជនអាចទាក់ទងតាមរយៈលេខទូរស័ព្ទ÷ ០១១ ៧៥ ៩៨ ៣៨។

ថ្ងៃ ព្រហស្បតិ៍ ៧កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០២៣

**រដ្ឋលេខាធិការ**

**និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

***ចម្លងជូន÷***

- *ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី កសហវ*
  *"ដើម្បីគោរពជូនជ្រាប"*
- *គ្រប់អង្គភាពក្រោមឱវាទ កសហវ*
- *គ្រប់ក្រសួង-ស្ថាប័ន*
  *"ដើម្បីគោរពជូនជ្រាប"*
- *ឯកសារ-កាលប្បវត្តិ*